Theology on the Web.org.uk

Making Biblical Scholarship Accessible

This document was supplied for free educational purposes. Unless it is in the public domain, it may not be sold for profit or hosted on a webserver without the permission of the copyright holder.

If you find it of help to you and would like to support the ministry of Theology on the Web, please consider using the links below:

Buy me a coffee https://www.buymeacoffee.com/theology

PATREON https://patreon.com/theologyontheweb

PayPal https://paypal.me/robbradshaw

---

A table of contents for *Honeycomb* can be found here:

https://biblicalstudies.org.uk/articles_honeycomb.php

HONEYCOMB 1/1 (July 2000): 68–72

# Meet Samoeun Intal

*UON Seila*



*Mrs. Samoeun Intal*

My father was a favorite son to his mom and family. His mother sent him to the temple to become a monk. But he left the monkhood and migrated to Vietnam to enlist as a soldier, where he was trained by the French military. Then he returned back to serve Cambodia. From there he was sent to fight in World War II. As a soldier, my father kept moving from one place to another to train soldiers.

I was the youngest of six children in my family. Whenever my father traveled about, I was the one who always traveled with him. On one occasion I attended a soldier's funeral and saw a military parade to honor the dead. Many people and high-ranking officials attended the funeral. My heart was so thrilled at this spectacle that I wanted to became a soldier to use my life in a valuable way. I'll never forget what my father told me: "Life is more precious than anything else. If you have everything and don't have life, everything is nothing."

In 1975, when the Khmer Rouge gradually surrounded Phnom Penh (the country was so dark by war that I wished to get away at that time), a family friend introduced me to a young Filipino who became my friend. He worked as an aircraft mechanic. I went with him to Kampong Som during the Khmer New Year but we never returned back to Phnom Penh as Cambodia fell to the Khmer Rouge. We fled to Thailand by boat with a lot of foreigners. In Thailand I married him and then moved on to the Philippines. When I first arrived there, I began to ask myself: "How will I use this precious gift called life?" One day I felt a strong call from the Lord to serve other precious lives by sharing with them the hope I had in the Lord Jesus.

My first contact with Christianity had been in a private English class in Cambodia during the early 70's when I was in junior high school. One day a girl I did not know came into my class and asked if she could sit in the vacant seat next to me. I had never seen her before, but I didn't object. She began to tell me about Jesus, his power and who he was. Although I understood little of what she said, I was interested and a seed was planted. I never saw that girl again.

In 1976, a year after coming to the Philippines, while studying English I began to feel lonely and detached. I longed for someone who really cared, for some real love, like the unconditional type of love some people receive from their parents. I had yet to know anything close to real love. The people in the world didn't care. They only cared about themselves. If you wanted to get their attention you had to have something to offer

them, not like the loving parents who always gave without expecting much in return.

During this lonely and depressing time, I watched a television evangelist preaching the gospel, but could only understand some of what he said. One evening in my English class my teacher, who was a missionary with Summer Institute of Linguistics, told me about a Khmer woman who worked for the Far East Broadcasting Company. At the same time, my teacher told her about me. This lady reached me and I went to visit her at the FEBC headquarters.

She shared for over an hour the good news of Jesus' work on the cross for the forgiveness of sins. But once again I understood little. She asked me if I realized that I was a sinner. This infuriated me. How could she presume anything about me? She didn't know me. She didn't know that our parents were devoted Buddhists who taught us always to do good! She then turned in the Bible to Romans 3:23 which read, "All have sinned and come short of the glory of God." That scripture penetrated to the depths of my heart, and I began to question myself. Am I clean, holy, and righteous? I thought about it for a while and somehow I couldn't say that I was really righteous or sinless. I had to acknowledge that I was a sinner of sorts. So right there in that office, with the other Khmer woman, I called on the name of the Lord for forgiveness of my sins. Somehow, I know very clearly that I would come back and work for that radio station.

God was carefully nurturing the seed he had planted in my heart, and as it grew I began to get a clear picture of God's plan for Cambodia. Over the next seventeen years that seed blossomed into a mature vision for my people that included establishing a facility inside Cambodia.

Cambodia was a prioritized nation from which to apply for immigration to a third country such as the United States, Australia, Canada, or France. But I turned down my application for immigration to one of these countries because I wanted to serve Cambodia instead of going abroad.

FEBC started Khmer language shortwave broadcasts from the Philippines in 1957. My own work with radio began nearly two decades later as a language assistant. My main responsibility was to edit scripts written by missionaries who had been forced to flee Cambodia when the Khmer Rouge came to power. These scripts were then broadcast from the Philippines into Cambodia. After four years of editing and broadcasting, I began to produce script myself. Although I had been able to escape physically from Cambodia, I could not escape mentally and emotionally from what my brothers and sisters were experiencing there during the twenty-five years of war. Although this could help me write heart-to-heart, it was often too painful and I wanted to quit. God always helped me to see what great opportunities there were in the radio ministry. This helped carry me through the difficult times.

In 1993, the Cambodian government granted FEBC permission to open an office and studio in Phnom Penh. When we first applied for a permission we did not volunteer our identity as Christians. Later that same year, our family pulled up stakes and relocated to Phnom Penh in order to train Khmer nationals to produce programs inside the country. But we still broadcast from the Philippines.

In 1995 we made clear to the government our identity as Christians. We established good contacts with the government and gained favor from them. FEBC submitted an application for setting up a radio station inside the country. The government offered us a station, but implementation of that offer was delayed due to the military clashes of July 1997. So we proceeded to bring in equipment to set up an AM radio station.

At last our radio equipment arrived at the port, but we could not clear customs to bring it in. We went back and forth with the Ministries of Information, Telecommunication, and Finance, but they said the government was not allowed to license a private AM station. After long negotiations, the government hinted that they wanted to have our AM equipment in exchange for granting us an FM frequency. Finally we yielded and agreed to apply for an FM frequency.

There have been further delays while we wait for the government to assign us a FM frequency. We want a high frequency, and they would rather give us a low one. We need God's wisdom to deal with such negotiations. We prayed to God for our patience to wait for God's timing on that issue. The Lord is good. He strengthens me when I felt weak.

One day I felt so frustrated. I asked myself, "Why did I choose radio ministry?" I sat on the porch of my office and watched a coconut palm tree moving. A question arose in my mind: "What makes the coconut palm tree move back and forth? The WIND! The wind is powerful. How much more powerful is the word of God in the air?" The word of God can prove itself strong if we put it on the air. It has power that can change lives. Life is very important!

Once the FM station goes on air, it will broadcast nine hours per day to a potential audience of six million people. We plan to broadcast in English in the future to help meet the English educational needs of this generation. After building trust with the government we also want to broadcast in Chinese and ethnic tribal languages in Rattakiri and Stung Treng.

We plan to set up substations in Kompong Thom, Kompong Chhang (working with Rev. K. P. Chhon), and other provinces as the Lord's will and blessing us. Please remember us in your prayers, and ask for God's provision as we serve Him.

*[Editor's note: Two days before this journal went to the printer, Rubledo and Samoeun's oldest son Abraham drowned in a tragic accident at Kampong Som. We dedicate this first issue of* Honeycomb *to Abraham's memory, and encourage our readers to remember the Intal family in their prayers.]*

សំណុំទឹកឃ្មុំ ១/១ (កក្កដា ២០០០): ៧៣-៧៨

# ការជួបជាមួយ លោកស្រី សាមឿន អ៊ីនតាល់

ដោយលោក អ៊ួន សិលា

*******



*លោកស្រី សាមឿន អ៊ីនតាល់*

ឪពុករបស់ខ្ញុំ ជាកូនដែលម្ដាយគាត់ស្រឡាញ់ពេញចិត្ត ហើយម្ដាយរបស់គាត់បានឲ្យគាត់ទៅបួសជាលោកសង្ឃ ដើម្បីសងគុណម្ដាយ ។ ប៉ុន្តែឪពុករបស់ខ្ញុំបានលាចាកសិក្ខាបទ ហើយបានរត់ទៅប្រទេសវៀតណាម ដើម្បីចូលធ្វើជាទាហាននៅទីនោះ គាត់ទទួលនូវការហ្វឹកហ្វឺន ពីកងយោធាបារាំង រួចគាត់ក៏បានវិលមកបំរើប្រទេសជាតិវិញ ។ គេបានបញ្ជូនគាត់ទៅប្រយុទ្ធក្នុងសង្គ្រាមលោកលើកទី ២ ។ ដោយសារតែឪពុកខ្ញុំជាទាហាន គាត់ផ្លាស់ពីកន្លែងមួយទៅកន្លែងមួយទៀត ដើម្បីហ្វឹកហ្វឺនដល់ពួកទាហាន ។

ខ្ញុំមានបងប្អូន ៦ នាក់ ហើយខ្ញុំជាប្អូនគេបង្អស់នៅក្នុងគ្រួសារ ។ នៅពេលដែលឪពុករបស់ខ្ញុំធ្វើដំណើរទៅណាមកណា គាត់តែងយកខ្ញុំទៅជាមួយ

គាត់ជានិច្ច ។ ខ្ញុំនៅចាំបាន ពេលមួយនោះខ្ញុំបានចូលរួមក្នុងពិធីបុណ្យសពរបស់ទាហានម្នាក់ ហើយខ្ញុំបានឃើញដំណើរហែរក្បួនរបស់ទាហាន ដើម្បីសម្តែងការគោរពដល់អ្នកដែលបានពលីជីវិតនោះ ។ មានមនុស្សជាច្រើន និង នាយទាហានដែលមាន ឋានន្តរសក្តិខ្ពង់ខ្ពស់ក៏បានចូលរួមដែរ ។ ខ្ញុំមានសេចក្តីរំភើបក្នុងចិត្តជាខ្លាំងចំពោះទិដ្ឋភាពនោះ ដែលធ្វើឲ្យខ្ញុំចង់ធ្វើជាទាហាន គឺចង់ប្រើជីវិតរបស់ខ្ញុំក្នុងផ្លូវមួយ ដែលមានតម្លៃបំផុតនោះ ។ ខ្ញុំនៅចាំមិនភ្លេចពីសំដីរបស់ឪពុករបស់ខ្ញុំបាននិយាយ មកកាន់ខ្ញុំថា : "ជីវិតមានតម្លៃលើសអ្វីៗទាំងអស់" ។ បើកូនមានអ្វីគ្រប់យ៉ាង ហើយគ្មានជីវិតនោះ គ្រប់យ៉ាងនឹងឥតប្រយោជន៍ទទេ" ។

នៅក្នុងឆ្នាំ ១៩៧៥ នៅពេលដែលពួកខ្មែរក្រហមហ៊ុំព័ទ្ធទីក្រុង ភ្នំពេញបន្តិចម្តងៗ ។ ខ្ញុំមានបំណងចង់ចាកចេញពីភាពងងឹតនៃប្រទេសជាតិ ពេលនោះខ្ញុំបានត្រូវញាតិមិត្តគ្រួសារ ណែនាំឲ្យស្គាល់បុរសម្នាក់ ដែលជាជនជាតិហ្វីលីពីនជាអ្នកជួសជុលយន្តហោះ ខ្ញុំក៏បានទៅជាគាត់ ក្នុងរយៈពេលចូលឆ្នាំថ្មី តែយើងមិនអាចវិលត្រលប់មកភ្នំពេញបានទេ ដោយប្រទេសខ្មែរបានធ្លាក់ទៅក្នុងកណ្តាប់ដៃខ្មែរក្រហម ។ យើងក៏បានចាកចេញពីកំពង់សោម ទៅប្រទេសថៃ ជាមួយជនជាតិបរទេសមួយចំនួនធំ តាមផ្លូវទឹក ។ នៅក្នុងប្រទេសថៃ ខ្ញុំបានរៀបការជាមួយមិត្តហ្វីលីពីន រួចបន្ទាប់មក ក៏មករស់នៅក្នុងប្រទេសហ្វីលីពីនវិញ ។ នៅពេលដែលខ្ញុំទៅដល់ប្រទេសភីលីពីន ដំបូងខ្ញុំចាប់ផ្តើមសួរខ្លួនឯងថា៖ "តើខ្ញុំត្រូវប្រើអំណោយដ៏មានតម្លៃ ដែលគេហៅថាជីវិតនេះ ដោយរបៀបណា?" ថ្ងៃមួយខ្ញុំបានដឹងយ៉ាងជាក់ច្បាស់ថា ព្រះជាម្ចាស់ត្រាស់ហៅខ្ញុំ ឲ្យបំពេញជីវិតដ៏មានតម្លៃ ដទៃទៀតដោយការផ្សាយពីសេចក្តីសង្ឃឹម ដែលខ្ញុំមានក្នុងព្រះជាម្ចាស់យេស៊ូ ចែកដល់ពួកគេ ។

ខ្ញុំបានដឹងឮពីជំនឿគ្រីស្ទបរិស័ទដំបូងបង្អស់ នោះគឺនៅពេលដែល ខ្ញុំកំពុងតែរៀនភាសាអង់គ្លេសនៅក្នុងសាលាឯកជនមួយនៅក្នុងស្រុកខ្មែរកាលពីឆ្នាំ ១៩៧៣ កាលនោះខ្ញុំនៅរៀនអនុវិទ្យាល័យនៅឡើយ ។ ថ្ងៃមួយនោះ មានយុវនារីម្នាក់ ដែលខ្ញុំមិនដែលស្គាល់សោះ បានមកថ្នាក់រៀនរបស់ខ្ញុំ ហើយបានសួរខ្ញុំថាតើនាងអាចចូលអង្គុយនៅក្នុងកន្លែងទំនេរនៅជាប់នឹងខ្ញុំបានទេ ។ ខ្ញុំមិនដែលបានជួបមិនដែលបានឃើញនាងពីមុនមកសោះ ប៉ុន្តែខ្ញុំមិនបានប្រកែកអ្វីឡើយ ។ នាងក៏ចូលមកអង្គុយ ហើយចាប់ផ្តើមនិយាយប្រាប់ខ្ញុំពីព្រះយេស៊ូ ពីព្រះចេស្តា

និង ពីបុគ្គលិកលក្ខណៈរបស់ព្រះអង្គ ។ ទោះបីជាខ្ញុំមិនយល់អ្វីបន្តិចសោះ នូវអ្វីដែលនាងព្យាយាមប្រាប់ខ្ញុំក៏ដោយ ខ្ញុំមានការចាប់អារម្មណ៍ ហើយពេលនោះ គ្រាប់ពូជមួយគ្រាប់បានដាំនៅក្នុងចិត្តរបស់ខ្ញុំ ។ តាំងពីនោះមកខ្ញុំមិនបានជួបនាងម្នាក់នោះឡើយ ។

នៅក្នុងឆ្នាំ ១៩៧៦ មួយឆ្នាំក្រោយពីខ្ញុំបានមកដល់ប្រទេស ភីលីពីន នៅដែលខ្ញុំកំពុងរៀនភាសាអង់គ្លេស ខ្ញុំចាប់ផ្ដើមមានអារម្មណ៍ធុញថប់ ត្រម៉ង់ត្រម៉ោចឯកោម្នាក់ឯង ។ ខ្ញុំចង់ឲ្យមានអ្នកណាម្នាក់ពិតជាថែរក្សា ផ្ដល់សេចក្ដីស្រឡាញ់ពិតប្រាកដ គឺជាសេចក្ដីស្រឡាញ់ឥតលក្ខ័ណ ដែលគេបានទទួលពីឪពុកម្ដាយ ។ ខ្ញុំមិនទាន់បានស្គាល់នូវសេចក្ដីស្រឡាញ់ ដែលដូចនឹងសេចក្ដីស្រឡាញ់ពិតប្រាកដនោះនៅឡើយ ។ មនុស្សនៅក្នុងលោកីយ៍នេះ គេមិនខ្វល់អ្វីឡើយ ចំពោះសេចក្ដីស្រឡាញ់ពិតនោះ ។ គេខ្វល់ខ្វាយតែពីខ្លួនគេផ្ទាល់ ។ បើយើងចង់ឲ្យគេយកចិត្តទុកដាក់នឹងយើង ទាល់តែយើងមានអ្វីឲ្យគេ ទើបគេយកចិត្តទុកដាក់នឹងយើង មិនដូចជាការស្រឡាញ់របស់ឪពុកម្ដាយ ដែលផ្ដល់មកដោយគ្មានសង្ឃឹមចង់បានការតបស្នងអ្វីទាំងអស់ ។

នៅក្នុងកំឡុងពេលដែលខ្ញុំនៅឯកោ និង ធ្លាក់ទឹកចិត្ត ខ្ញុំបានបើកទូរ-ទស្សន៍ មើលកម្មវិធីផ្សាយដំណឹងល្អ ប៉ុន្តែខ្ញុំយល់បានតិចតួចណាស់នូវដែលអ្នកផ្សាយដំណឹងល្អនោះបាននិយាយ ។ នៅល្ងាចមួយនៅក្នុងថ្នាក់រៀនភាសាអង់គ្លេស លោកគ្រូរបស់ខ្ញុំ ដែលជាបេសកជនធ្វើការនៅក្នុង Summer Institute of Linguistics បានប្រាប់ខ្ញុំថា មានស្ត្រីខ្មែរម្នាក់ធ្វើការនៅប៉ុស្តិ៍វិទ្យុ FEBC ។ នៅពេលជាមួយគ្នានោះ លោកគ្រូរបស់ខ្ញុំបានប្រាប់ដល់ស្ត្រីម្នាក់នោះអំពីរូបខ្ញុំ ដល់គាត់ម្នាក់នោះដែរ ។ ស្ត្រីម្នាក់នោះបានទាក់ទងខ្ញុំ ហើយខ្ញុំក៏បានទៅលេងគាត់ដល់ការិយាល័យ FEBC ។

គាត់បានជជែកជាមួយខ្ញុំប្រហែលមួយម៉ោង អំពីដំណឹងល្អនៃព្រះយេស៊ូដែលព្រះអង្គបានធ្វើ នៅលើឈើឆ្កាង ដើម្បីអត់ទោសបាប ។ តែម្ដងនេះខ្ញុំនៅតែយល់បានបន្តិចបន្តួច ។ គាត់បានសួរខ្ញុំថា តើខ្ញុំដឹងថាខ្ញុំជាមនុស្សមានបាបដែរឬទេ សំណួរបែបនេះធ្វើឲ្យខ្ញុំខឹងនឹងគាត់ ។ យ៉ាងម៉េចបានជាគាត់នេះអាចសន្និដ្ឋាន អំពីខ្ញុំបាន ? គាត់មិនដែលស្គាល់ខ្ញុំទេសោះ ។ គាត់មិនដឹងថា ឪពុកម្ដាយរបស់ខ្ញុំជាអ្នកកាន់សាសនាព្រះពុទ្ធដ៏ស្មោះស្ម័គ្រ ដែលតែងតែបង្រៀនដល់ខ្ញុំឲ្យធ្វើតែអំពើ

ល្អ ! ។ ក្រោយមកគាត់បានបើកព្រះគម្ពីរត្រង់ រ៉ូម ៣:២៣ ដែលចែងថា "គ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ" ។ បទគម្ពីរនោះបានជ្រាបចូលទៅក្នុងជម្រៅចិត្តរបស់ខ្ញុំ ហើយខ្ញុំចាប់ផ្តើមសួរខ្លួនឯងថា តើខ្ញុំស្អាតបរិសុទ្ធ ឬសុចរិតឬទេ ? ខ្ញុំបានគិតមួយស្របក់ ហើយខ្ញុំមិនអាចនិយាយអ្វីបានសោះ ដែលថាខ្ញុំពិតជាសុចរិត ឬ គ្មានបាបសោះនោះឡើយ ។ ខ្ញុំព្រមទទួលស្គាល់ថា ខ្ញុំជាមនុស្សមានបាប ។ ស្រាប់តែពេលនោះឯង ខ្ញុំព្រមថ្វាយខ្លួនដល់ព្រះអម្ចាស់ជាមួយនឹងស្ត្រីម្នាក់នោះ ដោយយាងព្រះអង្គមកក្នុងចិត្ត ឲ្យព្រះអង្គអត់ទោសបាបឲ្យខ្ញុំ ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំដឹងយ៉ាងច្បាស់ថា ខ្ញុំនឹងត្រលប់មកវិញនឹងធ្វើការនៅក្នុងស្ថាប័នវិទ្យុ ។

ព្រះជាម្ចាស់បានថែគ្រាប់ពូជ ដែលបានដាំក្នុងចិត្តរបស់ខ្ញុំដោយប្រុងប្រយ័ត្ន ហើយនៅពេលដែលគ្រាប់ពូជនោះដុះឡើង ខ្ញុំបានដឹងច្បាស់ថា ជាផែនការរបស់ព្រះជាម្ចាស់សំរាប់ប្រទេសកម្ពុជា ។ អស់រយៈពេល ១៧ ឆ្នាំ ក្រោយមកគ្រាប់ពូជនោះបានដុះដាលឡើងជានិមិត្តដ៏ធំមួយ សំរាប់ប្រជាជនរបស់ខ្ញុំ ដែលការនោះគិតទាំងការបើកឲ្យមានការបង្កើតការផ្សាយនៅក្នុងប្រទេសកម្ពុជា ។

ប្រទេសកម្ពុជា គឺជាប្រទេសមានអាទិភាពជាងប្រទេសនានា ក្នុងការដាក់ពាក្យទៅសុំការតាំងទីលំនៅក្នុងប្រទេសទី ៣ ដូចជាប្រទេសអាមេរិក អូស្ត្រាលី កាណាដា ឬ ក៏ប្រទេសបារាំង ។ ប៉ុន្តែខ្ញុំបានបោះបង់ចោលចំពោះការដាក់ពាក្យសុំទៅចូលទៅតាំងទីលំនៅក្នុងប្រទេសទាំងនោះ ពីព្រោះខ្ញុំចង់ទៅបំរើប្រទេសខ្មែរជាជាងចេញទៅបរទេស ។

FEBC ចាប់ផ្តើមផ្សាយជាភាសាខ្មែរ តាមរលកធាតុអាកាសខ្លីពីប្រទេសភីលីពីន នៅក្នុងឆ្នាំ ១៩៥៧ ។ ការងាររបស់ខ្ញុំជាមួយវិទ្យុចាប់ផ្តើមជិតពីទសវត្សរ៍ក្នុងឋានៈជាអ្នកជំនួយផ្នែកភាសា ។ ការទទួលខុសត្រូវសំខាន់របស់ខ្ញុំ គឺពិនិត្យមើលអត្ថបទរបស់ពួកបេសកជន ដែលត្រូវពួកខ្មែរក្រហមបង្ខំឲ្យចាកចេញពីប្រទេសខ្មែរ កាលកំឡុងពេលខ្មែរក្រហមកាន់អំណាចនោះ បានសរសេរមកឲ្យយើង ។ អត្ថបទនេះបានផ្សាយមកក្នុងស្រុកខ្មែរ ចេញពីប្រទេសភីលីពីន ។ បន្ទាប់ពីធ្វើការកាត់ត អត្ថបទ និង ការផ្សាយអស់រយៈពេល ៤ ឆ្នាំ ក្រោយមកខ្ញុំក៏ចាប់ផ្តើមផលិតកម្មវិធីនោះ ដោយខ្លួនឯង ។ ទោះបីជាខ្ញុំបានរត់គេចរួចខ្លួនមែនពីប្រទេសកម្ពុជា តែខ្ញុំមិនគេចឲ្យរួចពីការនឹកគិតដល់បងប្អូនប្រុសស្រីរបស់ខ្ញុំ ដែល

ឆ្លងកាត់សង្គ្រាមជាង ២៥ ឆ្នាំ នោះឡើយ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ការនេះអាចជួយឲ្យខ្ញុំអាចសរសេរ ចេញពីចិត្តរបស់ខ្ញុំ ដែលសម្ដែងពីការរងឈឺចាប់ដែលបងប្អូនមាននៅក្នុងស្រុក ខ្ញុំមានការឈឺចាប់ណាស់ ហើយពេលខ្លះ ខ្ញុំចង់ឈប់ពីការងារនេះ ។ ព្រះជាម្ចាស់តែងតែជួយខ្ញុំ ឲ្យឃើញនូវឱកាសដ៏ធំធេងនៅក្នុងព័ន្ធកិច្ចវិទ្យុ ។ ព្រះជួយខ្ញុំឲ្យឆ្លងកាត់នូវការលំបាកជាច្រើនដងច្រើនលើក ។

នៅក្នុងឆ្នាំ ១៩៩៣ រាជរដ្ឋាភិបាលកម្ពុជា បានផ្ដល់ឲ្យច្បាប់ដល់ FEBC ដើម្បីឲ្យបើកការិយាល័យ និង បន្ទប់ថតសម្លេងមួយនៅក្នុងទីក្រុង ភ្នំពេញ ។ នៅពេលដែលយើងដាក់ពាក្យសុំច្បាប់ជាលើកដំបូង យើងមិនបង្ហាញពីអត្តសញ្ញាណរបស់យើងឲ្យរដ្ឋាភិបាលស្គាល់ថា យើងជាគ្រីស្ទបរិស័ទទេ ។ ក្រោយមកក្នុងឆ្នាំដដែលនោះ គ្រួសាររបស់យើងផ្លាស់ទីលំនៅពី ភីលីពីន មកនៅក្នុងប្រទេសកម្ពុជា នាទីក្រុងភ្នំពេញ ដើម្បីហ្វឹកហ្វឺនជនជាតិខ្មែរ ឲ្យផលិតកម្មវិធីផ្សាយនៅក្នុង ប្រទេស។ ប៉ុន្តែយើងនៅតែផ្សាយចេញពីប្រទេស ភីលីពីន ដដែល ។

នៅក្នុងឆ្នាំ ១៩៩៥ យើងបានបង្ហាញពីអត្តសញ្ញាណរបស់យើងឲ្យរដ្ឋាភិបាលស្គាល់យើងច្បាស់ថា យើងជាគ្រីស្ទបរិស័ទ ។ យើងបានរឹតចំណងទាក់ទងដ៏ប្រសើរជាមួយរាជរដ្ឋាភិបាល ។ FEBC បានដាក់ពាក្យសុំបើកស្ថានីយ៍វិទ្យុផ្សាយសម្លេងនៅក្នុងប្រទេស ។ រាជរដ្ឋាភិបាលបានផ្ដល់ឲ្យយើងបើកស្ថានីយ៍វិទ្យុមួយ ប៉ុន្តែការផ្ដល់ច្បាប់នោះត្រូវអាក់ខាន ដោយសារមានព្រឹត្តិការណ៍ប៉ះទង្គិចគ្នាផ្នែកយោធា កាលពីខែ កក្កដា ១៩៩៧ ។ ដូច្នេះយើងបានចាប់ផ្ដើមដំណើរការនាំសម្ភារៈចូលមក ដើម្បីតម្លើងស្ថានីយ៍វិទ្យុ AM ។

ទីបំផុតសម្ភារៈវិទ្យុរបស់យើង បានមកដល់កំពង់ផែ ប៉ុន្តែគយមិនអនុញ្ញាតឲ្យយើងនាំចូលមកឡើយ ដោយមានបញ្ហាខ្លះៗដោះស្រាយមិនរួច ។ យើងបានចុះឡើង ទាក់ទងគ្រប់ក្រសួងដែលពាក់ព័ន្ធ ដូចជាក្រសួងពត៌មានទូរគមនាគមន៍ និង ក្រសួងហិរញ្ញវត្ថុ ប៉ុន្តែរដ្ឋាភិបាលបានប្រាប់យើងថា គេមិនអាចអនុញ្ញាតច្បាប់ឲ្យអាជ្ញាប័ណ្ណឲ្យបើកស្ថានីយ៍វិទ្យុ AM ជាឯកជនឡើយ ។ បន្ទាប់ពីចរចារយ៉ាងយូរ រដ្ឋាភិបាលបានប្រលយពាក្យឲ្យយើងដឹងថា រដ្ឋាភិបាលចង់បានសម្ភារៈស្ថានីយ៍ AM របស់យើង ដើម្បីប្ដូរនឹងការផ្ដល់ច្បាប់បើកស្ថានីយ៍ FM ។ ទីបំផុតយើងក៏ព្រមប្រគល់ឲ្យ ហើយយល់ព្រមដាក់ពាក្យសុំបើកស្ថានីយ៍ FM ជំនួសវិញ ។

មានការយឺតយ៉ាវយ៉ាងយូរ យើងរង់ចាំរដ្ឋាភិបាលផ្តល់ស្ថានីយ៍ FM ឲ្យយើង ។ យើងចង់បានកម្លាំងខ្លាំង តែរដ្ឋាភិបាលឲ្យយើងផ្សាយកម្លាំងខ្សោយ ។ យើងត្រូវការប្រាជ្ញាពីព្រះជាម្ចាស់ក្នុងការចរចារបែបហ្នឹង ។ យើងបានអធិស្ឋានឲ្យយើងខ្ញុំមានការអត់ធ្មត់ រង់ចាំពេលរបស់ព្រះជាម្ចាស់ចំពោះការងារនេះ ។ ព្រះអង្គទ្រង់ល្អ ! ព្រះអង្គផ្តល់កម្លាំងឲ្យខ្ញុំនៅពេលដែលខ្ញុំខ្សោយ ក្រោយមកគេក៏ឲ្យកម្លាំងដ៏ខ្លាំងល្អឲ្យយើង ។

ថ្ងៃមួយខ្ញុំមានអារម្មណ៍ខ្វល់ខ្វាយយ៉ាងខ្លាំង ។ ខ្ញុំបានសួរខ្លួនថា: “ហេតុអ្វីបានជាខ្ញុំជ្រើសរើសព័ន្ធកិច្ចវិទ្យុ ? ” ខ្ញុំបានអង្គុយនៅរានហាលនៃការិយាល័យរបស់ខ្ញុំ ហើយខ្ញុំបានសម្លឹងមើលធាងដូងបក់ចុះបក់ឡើង ។ ខ្ញុំឆ្ងល់នៅក្នុងគំនិតរបស់ខ្ញុំ : “ តើអ្វីដែលធ្វើឲ្យធាងដូងបក់ចុះបក់ឡើង ? ខ្យល់ ! ខ្យល់មានអំណាចណាស់ ។ តើព្រះបន្ទូលមានអំណាច ចេស្តា ប៉ុណ្ណាទៅ បើយើងដាក់ព្រះបន្ទូលនោះ ទៅក្នុងខ្យល់ ? ” ព្រះបន្ទូលរបស់ព្រះជាម្ចាស់បង្ហាញយ៉ាងច្បាស់ថា នឹងមានអំណាចចេស្តា បើយើងដាក់ព្រះបន្ទូលនោះបញ្ជូលតាមរលកធាតុអាកាស ។ ព្រះបន្ទូលអាចបំផ្លាស់បំប្រែជីវិត ។ ជីវិតគឺជារបស់សំខាន់បំផុត !

នៅពេលដែលស្ថានីយ៍ FM ចេញផ្សាយ គឺផ្សាយ ៩ ម៉ោង ក្នុងមួយថ្ងៃ កម្លាំងវិទ្យុនោះអាចធ្វើឲ្យមនុស្ស ៦ លាន នាក់ស្តាប់ឮ យើងមានគម្រោងផែនការផ្សាយជាភាសាអង់គ្លេស នៅថ្ងៃអនាគត ដើម្បីជួយអប់រំផ្នែកភាសាអង់គ្លេសដល់មនុស្សជំនាន់នេះ ។ បន្ទាប់ពីបង្កើនការទុកចិត្តជាមួយរដ្ឋាភិបាលរួចហើយ យើងចង់ផ្សាយជាភាសាចិន និង ភាសាជនជាតិភាគតិចនៅខេត្ត រតនៈគីរី និង ស្ទឹងត្រែង ។

យើងមានផែនការបង្កើតសាខាស្ថានីយ៍ នៅតាមបណ្តាខេត្តដូចជាខេត្តកំពង់ធំ កំពង់ឆ្នាំង (ធ្វើការជាមួយលោកគ្រូ គង់ ផនឆុន ) ហើយនិង បន្តទៅខេត្តផ្សេងៗទៀត តាមតែព្រះទ្រង់ប្រទានពរ និង ដឹកនាំ ។

សូមជួយអធិស្ឋានដល់យើងខ្ញុំ សូមឲ្យព្រះជាម្ចាស់ផ្គត់ផ្គង់យើងខ្ញុំ ក្នុងការដែលយើងបំរើព្រះអង្គ ។

*(សេចក្តីបន្ថែមរបស់បណ្ណាធិការ: ពីរថ្ងៃមុនព្រឹត្តិប័ត្របានបោះពុម្ព កូនច្បងរបស់លោក រូប៉េដូ និង លោកស្រី សាមឿន អ៊ិនតាល់ ឈ្មោះ អាប្រាហាម បានលង់ទឹកស្លាប់នៅក្នុងឧប្បត្តិហេតុមួយគួរអោយសង្វេគនៅសមុទ្រក្រុងកំពង់សោម ។ យើងសូមឧទ្ទិសការចេញផ្សាយរបស់ព្រឹត្តិប័ត្រសំណុំទឹកឃ្មុំទី១ នេះ ទុកជាការចងចាំដល់អាប្រាហាម ហើយនិងសូមលើកទឹកចិត្តដល់អ្នកអានរបស់យើង នឹកចាំពីគ្រួសារ សាមឿន អ៊ិនតាល់ នៅក្នុងសេចក្តីអធិស្ឋានរបស់យើងផង ។)*